# ស្ថានទូតអូស្ត្រាលី
# ភ្នំពេញ
# សេចក្តីប្រកាសព័ត៌មាន

## ផ្សព្វផ្សាយតាមរយៈកីឡាៈ អង្គការក្នុងស្រុកទទួលបានប្រាក់ជំនួយ ពីគណៈកម្មការកីឡាអូស្ត្រាលី

ប្រាក់ជំនួយចំនួន ១៥,០០០ដុល្លាអូស្ត្រាលី ក្រោមកម្មវិធីផ្សព្វផ្សាយវិស័យកីឡាអូស្ត្រាលី ត្រូវបានផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដែលមានឈ្មោះថា អិនដូរឆាយណាស្តាហ្វិស ហ្វោនដេឆិន (Indochina Starfish Foundation) សំរាប់ឆ្នាំ២០១០ និង ២០១១ ។

កម្មវិធីជំនួយអភិវឌ្ឍន៍កីឡារបស់គណៈកម្មការកីឡាអូស្ត្រាលី ផ្តល់ជំនួយលើការអភិវឌ្ឍន៍សហគមន៍តាមរយៈកម្មវិធីកីឡានៅប្រទេសឥណ្ឌា អាហ្វ្រិកខាងត្បូង ប៉ាស៊ីហ្វិក និងការីប៊ីន ។ កម្មវិធីនេះផ្តល់ថវិកាដោយភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី ហើយគ្រប់គ្រងដោយគណៈកម្មការកីឡាអូស្ត្រាលី ។

បន្ទាប់ពីបានពិនិត្យលើពាក្យស្នើរសំដែលមានចំនួនជាង១៣០រួចមក គណៈកម្មការកីឡាអូស្ត្រាលីបានសំរេចផ្តល់ប្រាក់ជំនួយចំនួន២៣គំរោងថ្មីទៀតដល់ប្រទេសចំនួន១៩ ដោយគាំទ្រការបន្តលើគំរោង៥បន្ថែមទៀត សរុបទាំងអស់មាន២១ប្រទេស ហើយទឹកប្រាក់សរុបទាំងអស់រួមមាន៣៩៨,០០០ដុល្លាអូស្ត្រាលី សំរាប់ឆ្នាំ២០១០ និង ២០១១ ។

លោកស្រី **ខេត គ្រហ្វីន** (Kate Griffin) អ្នកគ្រប់គ្រងប្រចាំប្រទេសនៃអង្គការ អិនដូរឆាយណាស្តាហ្វិសហ្វោនដេឆិន បានមានប្រសាសន៍ថា " យើងពិតជាសប្បាយចិត្តយ៉ាងក្រៃលែងដោយបានទទួលនូវជំនួយថវិការទាំងនេះ ។ ថវិការទាំងនេះនឹងមានផលប្រយោជន៍យ៉ាងខ្លាំងដល់កុមារា កុមារីជាង២៥០០នាក់ ហើយនេះជាការផ្តល់ឪកាសដល់ពួកគេបានចូលរួមក្នុងកម្មវិធីបាល់ទាត់របស់យើង ដែលធ្វើអោយពួកគេមានសុខភាពល្អ មានការជឿជាក់លើខ្លួនឯង និងមានស្មារតីជាក្រុម " ។

No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

អង្គការអិនជូរឆោយណាស្តាហ្វិសហ្វោនដេផិន នឹងប្រើប្រាស់ជំនួយថវិការនេះដើម្បីកសាងសមត្ថភាពបុគ្គលឹក និងគ្រូកីឡាដែលបង្រៀនកម្មវិធីបាល់ទាត់ដល់កុមារមកពីមណ្ឌលកុមារកំព្រា និងអង្គការវិថីនៅភ្នំពេញ ខេត្តកណ្តាល ព្រៃវែង និងបាត់ដំបង ក្នុងភាពជាដៃគូរជាមួយសហព័ន្ធបាល់ទាត់កម្ពុជា និងបណ្ឌិតសភាហ្វីកហ្វីនភាពជាអ្នកដឹកនាំ និងកីឡា ។ កម្មវិធីហ្វីកហ្វីនផ្តោតសំខាន់លើការអភិវឌ្ឍន៍ជំនាញកីឡា ភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រង ក៏ដូចជាការហាត់រៀនពីការសង្គ្រោះបឋមផងដែរ ។

កម្មវិធីជំនួយអភិវឌ្ឍន៍កីឡាគាំទ្រដល់ ការកើនឡើងនៃការចូលរួមរបស់សហគមន៍ក្នុងសកម្មភាពកីឡា និងកាយសម្បទា ។ កម្មវិធីនេះក៏មានបំណងគាំទ្រដល់គំរោងទាំងឡាយណាដែលអាចផ្តល់ជាយានការប្រកបដោយប្រសិទ្ធភាពមួយក្នុងការដោះស្រាយបញ្ហាសហគមន៍អោយបានទូលំទូលាយដូចជាការលើកស្ទួយវិស័យសុខាភិបាល ភាពជាអ្នកដឹកនាំ និងការសាមគ្គីគ្នា តាមរយៈសកម្មភាពកីឡា និងកាយសម្បទា ។ មានការផ្តោតអារម្មយ៉ាងខ្លាំងលើការផ្តល់ការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍទាំងឡាយ និង លើកទឹកចិត្តអោយមានការចូលរួមដោយស្មើភាពគ្នាពីសំណាក់ស្ត្រី និងកុមារីផងដែរ ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង:
លោកស្រី **ហ្វីយ៉ូណា ខូឆូ** ស្ថានទូតអូស្ត្រាលី ភ្នំពេញ
ទូរស័ព្ទលេខ: ០២៣ ២១៣ ៩៧០
ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១០